រដ្ឋសភា
ចូល លេខ ២៥៧២ ថ្ងៃទី ១៨/៧ ឆ្នាំ ២០១៩ ម៉ោង ១៤:៤០
បញ្ជូនទៅ ...

# ព្រះរាជក្រម

នស/រកម/០៧១៩/០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL •

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងប្រេងកាតនិង
# ផលិតផលប្រេងកាត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងជំរុញអភិវឌ្ឍវិស័យប្រេងកាតប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងផលប្រយោជន៍យូរអង្វែងរបស់ប្រទេសជាតិ។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់អំពីសមត្ថកិច្ចនិងវិធាននៃការគ្រប់គ្រងវិស័យប្រេងកាត។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាពក្នុងវិស័យប្រេងកាតនៅក្នុងបូរណភាពទឹកដីនិង អធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជារួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចកំណត់នៅក្នុងសទ្ទានុក្រមជាឧបសម្ព័ន្ធ។

## ជំពូកទី២
## សមត្ថកិច្ចនិងការគ្រប់គ្រង

**មាត្រា៥ .-**

ធនធានប្រេងកាតទាំងអស់គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ។

**មាត្រា៦ .-**

ក្រសួងរ៉ែនិងថាមពលជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនិងត្រួតពិនិត្យរាល់សកម្មភាពក្នុងវិស័យប្រេងកាត។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងធ្វើសកម្មភាពក្នុងវិស័យប្រេងកាតត្រូវសុំការអនុញ្ញាតពីក្រសួងរ៉ែនិងថាមពល។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចធ្វើប្រតិភូកម្មមុខងារនិងធនធានជូនថ្នាក់ក្រោមជាតិលើសកម្មភាពមួយចំនួនក្នុងវិស័យប្រេងកាតតាមនីតិវិធីជាធរមាន។

**មាត្រា៧ .-**

ការគ្រប់គ្រងវិស័យប្រេងកាតត្រូវផ្អែកលើគោលការណ៍តម្លាភាព គណនេយ្យភាព សមធម៌ក្នុងវឌ្ឍនភាពសង្គមនិងសុខុមាលភាពសាធារណៈ សន្តិសុខនិងសុវត្ថិភាព និងការទទួលខុសត្រូវបរិស្ថាន។

ដើម្បីអនុវត្តគោលការណ៍នេះឱ្យមានប្រសិទ្ធភាព ការគ្រប់គ្រងវិស័យប្រេងកាតត្រូវធានាឱ្យបាននូវ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS

- ផលប្រយោជន៍ជាតិជាអតិបរមា
- ឧត្តមានុវត្តក្នុងសកម្មភាពផ្នែកអាប់ស្ទ្រីមនិងដោនស្ទ្រីម
- ការផ្គត់ផ្គង់ផលិតផលប្រេងកាតប្រកបដោយគុណភាព បរិមាណ និងថ្លៃ ដែលរួមចំណែកពង្រឹងសន្តិសុខថាមពលជាតិ
- ការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន ការកាត់បន្ថយការបំពុលបរិស្ថាន និងការស្តារបរិស្ថានឡើងវិញ
- សក្តិសិទ្ធភាពនៃការត្រួតពិនិត្យលើការអនុវត្តវិធានគ្រប់គ្រងលើសុវត្ថិភាពនិងលក្ខខណ្ឌសុខភាពការងារ
- ការកសាង ជំរុញ និងលើកតម្កើងសមត្ថភាពជាតិទាំងផ្នែកបច្ចេកទេសនិងធុរកិច្ចក្នុងវិស័យប្រេងកាត
- ការបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋនិងសេវាកម្មក្នុងស្រុក
- ការបង្កើនចំណូលថវិកាជាតិនិងរួមចំណែកក្នុងការជំរុញពិពិធកម្មនិងភាពប្រកួតប្រជែងនៃវិស័យឧស្សាហកម្មនិងពាណិជ្ជកម្មរបស់ជាតិ និង
- ការបង្កើតផលប្រយោជន៍ផ្ទាល់ដល់សហគមន៍មូលដ្ឋាននិងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ប្រតិបត្តិការប្រេងកាត។

## ជំពូកទី៣
## ការគ្រប់គ្រងសកម្មភាពផ្នែកអាប់ស្ទ្រីម

**មាត្រា៨ .-**

សកម្មភាពផ្នែកអាប់ស្ទ្រីមរួមមានបុរេសនា ការស្វែងរុករក ការអភិវឌ្ឍ និងផលិតកម្មប្រេងកាត។

**មាត្រា៩ .-**

រាល់សកម្មភាព ស្វែងរុករក អភិវឌ្ឍ និងផលិតកម្មប្រេងកាតត្រូវមានកិច្ចព្រមព្រៀងប្រេងកាត។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវស្នើសុំការអនុញ្ញាតជាមុនពីនាយករដ្ឋមន្ត្រីដើម្បីចុះកិច្ចព្រមព្រៀងប្រេងកាតស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

លក្ខខណ្ឌនិងនីតិវិធីនៃការជ្រើសរើសអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលមានសិទ្ធិស្នើសុំធ្វើបុរេសនា។ ចំពោះនីតិបុគ្គលដែលបានទទួលការអនុញ្ញាតធ្វើបុរេសនានៅតំបន់ណាមួយ នីតិបុគ្គលនោះមានសិទ្ធិស្នើសុំចុះកិច្ចព្រមព្រៀងប្រេងកាតក្នុងប្លុកប្រេងកាតណាមួយនៅក្នុងតំបន់នោះ ប៉ុន្តែសិទ្ធិស្នើសុំនេះពុំមែនជាសិទ្ធិផ្តាច់មុខទេ។

រាល់សកម្មភាពបុរេសនាត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតឱ្យធ្វើបុរេសនាត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា១១ .-**

នីតិបុគ្គលដែលអាចអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងប្រេងកាតបានមានដូចខាងក្រោម៖

- សហគ្រាសសាធារណៈដែលបង្កើតឡើងស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន
- ក្រុមហ៊ុនមូលធនដែលបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលធ្វើសកម្មភាពធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១២ .-**

កិច្ចព្រមព្រៀងប្រេងកាតស្របតាមបញ្ញត្តិនៃច្បាប់នេះត្រូវកំណត់ចំណុចសំខាន់ៗជាអប្បបរមាដូចខាងក្រោម៖

ក- ចំណូលរដ្ឋពីប្រេងកាត។

ខ- ការចូលរួមភាគហ៊ុនរបស់រដ្ឋ។

គ- យន្តការបែងចែកផលប្រេងកាត។

ឃ- សោហ៊ុយប្រេងកាតនិងការកាត់កង។

ង- តំបន់ចុះកិច្ចព្រមព្រៀងនិងការប្រគល់ផ្ទៃក្រឡាសងវិញ។

ច- កាតព្វកិច្ចការងារអប្បបរមានិងគម្រោងចំណាយ។

ឆ- កំណត់ចំណុចផ្ទេរទទួលពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិជាម្ចាស់លើចំណែកផលប្រេងកាត។

ជ- រយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងនិងលក្ខខណ្ឌនៃការបញ្ចប់និងការពន្យារបន្តសុពលភាព។

ឈ- កាតព្វកិច្ចផ្គត់ផ្គង់ប្រេងកាតដើម្បីបំពេញតម្រូវការក្នុងស្រុក។

ញ- កាតព្វកិច្ចក្រោយការបញ្ចប់ប្រតិបត្តិការប្រេងកាតនិងការស្តារបរិស្ថានឡើងវិញ។

ដ- កាតព្វកិច្ចសុវត្ថិភាព សន្តិសុខ និងបរិស្ថាន ក្នុងប្រតិបត្តិការប្រេងកាត។

ឋ- លក្ខខណ្ឌក្នុងការលក់ឬផ្ទេរសិទ្ធិភាគហ៊ុន។

ឌ- កាតព្វកិច្ចផ្តល់របាយការណ៍និងទិន្នន័យ។

ឍ- ផែនការអភិវឌ្ឍនិងផលិតកម្មប្រេងកាត។

ណ- កាតព្វកិច្ចផ្តល់ការបណ្តុះបណ្តាលនិងកសាងសមត្ថភាពស្ថាប័នក្នុងវិស័យប្រេងកាត។

ត- កាតព្វកិច្ចប្រើប្រាស់កម្លាំងពលកម្ម ទំនិញ និងសេវាកម្មក្នុងស្រុក។

ថ- កាតព្វកិច្ចចូលរួមអភិវឌ្ឍនិងលើកកម្ពស់សុខុមាលភាព និងការការពារសិទ្ធិរបស់សហគមន៍មូលដ្ឋាន។

ទ- ការដោះស្រាយវិវាទ។

**មាត្រា១៣ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតមួយមិនអាចទទួលបានប្លុកប្រេងកាតលើសពី២ (ពីរ)ឡើយ។ ប្លុកប្រេងកាតនីមួយៗនឹងត្រូវបានចុះកិច្ចព្រមព្រៀងប្រេងកាតដោយឡែកៗពីគ្នា។

**មាត្រា១៤ .-**

ក្រសួងរ៉ែនិងថាមពលត្រូវកំណត់បែងចែកប្លុកប្រេងកាតដោយមាននិយាមការជាក់លាក់យោងតាមលក្ខណៈភូគព្ភសាស្ត្រ។

មុននឹងបើកប្លុកប្រេងកាតណាមួយដើម្បីជ្រើសរើសអ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ក្រសួងរ៉ែនិងថាមពលអាចចាត់ចែងឱ្យមានការវិភាគវាយតម្លៃបឋមអំពីលក្ខណៈសេដ្ឋកិច្ចនិងសង្គម កម្រិតហានិភ័យនិងផលប៉ះពាល់បរិស្ថាន។

**មាត្រា១៥ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតទទួលបានសិទ្ធិជាម្ចាស់លើចំណែកផលប្រេងកាតរបស់ខ្លួននៅចំណុចផ្ទេរទទួល ក្រោយពីធនធានប្រេងកាតនោះត្រូវបានផលិតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា១៦ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតផ្នែកអាប់ស្ទ្រីមដែលមានបំណងធ្វើសកម្មភាពផ្នែកដោនស្ទ្រីមត្រូវចុះបញ្ជីពាណិជ្ជកម្មជានីតិបុគ្គលដោយឡែកផ្សេងមួយទៀត។

**មាត្រា១៧ .-**

កិច្ចព្រមព្រៀងប្រេងកាតត្រូវមានរយៈពេលសុពលភាពមិនលើសពី៣០(សាមសិប)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតអាចស្នើសុំពន្យារបន្តសុពលភាពនេះបាន ប៉ុន្តែរយៈពេលសរុបនៃការពន្យារបន្តសុពលភាពមិនត្រូវលើសពី១៥(ដប់ប្រាំ)ឆ្នាំ។

រយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងប្រេងកាតត្រូវបែងចែកជាពីរគឺរយៈពេលស្វែងរុករក និងរយៈពេលអភិវឌ្ឍនិងផលិតកម្ម។ រយៈពេលស្វែងរុករកមិនត្រូវលើសពី៧(ប្រាំពីរ)ឆ្នាំនិងអាចស្នើសុំពន្យារបន្តសុពលភាពបាន ដែលរយៈពេលសរុបនៃការពន្យារបន្តសុពលភាពមិនត្រូវលើសពី៣(បី)ឆ្នាំ។

លក្ខខណ្ឌនិងនីតិវិធីនៃការពន្យារបន្តសុពលភាពកិច្ចព្រមព្រៀងប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៨ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតមានសិទ្ធិស្នើសុំបន្ត កែប្រែសិទ្ធិនិងផលប្រយោជន៍ ដាក់ជាប្រាតិភោគ ផ្ទេរសិទ្ធិ ប្តូរអំណាចគ្រប់គ្រង ឬបន្តជាសន្តតិកម្ម កិច្ចព្រមព្រៀងប្រេងកាតបាន។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំបន្ត កែប្រែសិទ្ធិនិងផលប្រយោជន៍ ដាក់ជាប្រាតិភោគ ផ្ទេរសិទ្ធិ ប្តូរអំណាចគ្រប់គ្រង ឬបន្តជាសន្តតិកម្ម កិច្ចព្រមព្រៀងប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៩ .–**

កិច្ចព្រមព្រៀងប្រេងកាតអាចត្រូវបានព្យួរឬបញ្ចប់ក្នុងករណីដែលអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតមិនបានបំពេញកាតព្វកិច្ចស្របតាមកិច្ចព្រមព្រៀងប្រេងកាតឬបទប្បញ្ញត្តិនៃច្បាប់នេះ។

លក្ខខណ្ឌនិងនីតិវិធីនៃការព្យួរនិងការបញ្ចប់កិច្ចព្រមព្រៀងប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ .–**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវមានកាតព្វកិច្ចសំខាន់ៗដូចខាងក្រោម៖

ក- ធ្វើប្រតិបត្តិការឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមលក្ខណៈបច្ចេកទេស ឧត្តមានុវត្ត និងបទដ្ឋានអន្តរជាតិ។

ខ- ការពារបរិស្ថាននិងសង្គម សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ធ្វើផែនការគ្រប់គ្រងបរិស្ថាន និងធ្វើផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។

គ- ការពារសុខភាពនិងសុវត្ថិភាពការងារ។

ឃ- ការពារសុវត្ថិភាពសាធារណៈនៅក្នុងនិងនៅជុំវិញតំបន់ការដ្ឋានផលិតកម្មប្រេងកាត។

ង- ផ្តល់ការអប់រំ បណ្តុះបណ្តាល និងផ្តល់អាទិភាពការងារដល់ប្រជាពលរដ្ឋខ្មែរ។

ច- ធ្វើការចូលរួមអភិវឌ្ឍសហគមន៍មូលដ្ឋាន លើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាជននៅមូលដ្ឋានជុំវិញតំបន់ការដ្ឋានផលិតកម្ម។

ឆ- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកម្លាំងពលកម្ម ទំនិញ និងសេវាកម្មក្នុងស្រុក។

ជ- ផ្តល់របាយការណ៍ស្តីពីប្រតិបត្តិការប្រេងកាតជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពល។

ឈ- អនុវត្តស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា២១ .–**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលអំពីការរកឃើញធនធានប្រេងកាតនិង/ឬការរកឃើញធនធានប្រេងកាតដែលមានលក្ខណៈពាណិជ្ជកម្ម ដើម្បីស្នើសុំការអនុញ្ញាតអភិវឌ្ឍនិងផលិតកម្មប្រេងកាត។ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវស្នើសុំគោលការណ៍ឯកភាពពីនាយករដ្ឋមន្ត្រីមុននឹងផ្តល់ការអនុញ្ញាតធ្វើការអភិវឌ្ឍនិងផលិតកម្មប្រេងកាត។

លក្ខខណ្ឌ និងនីតិវិធីនៃការជូនដំណឹងអំពីការរកឃើញធនធានប្រេងកាតនិងការអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍ និងផលិតកម្មប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២ .–**

ក្នុងករណីធនធានប្រេងកាតដែលបានរកឃើញមានលក្ខណៈត្រឹមតែសក្តានុពលពាណិជ្ជកម្ម អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើការអភិវឌ្ឍនិងផលិតកម្មប្រេងកាតមានលក្ខខណ្ឌមកក្រសួងរ៉ែនិងថាមពល។ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវស្នើសុំគោលការណ៍ឯកភាពពីនាយករដ្ឋមន្ត្រីមុននឹងផ្តល់ការអនុញ្ញាតធ្វើការអភិវឌ្ឍនិងផលិតកម្មប្រេងកាតមានលក្ខខណ្ឌ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ការអនុញ្ញាតធ្វើការអភិវឌ្ឍនិងផលិតកម្មប្រេងកាតមានលក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៣ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលខកខានមិនបានអនុវត្តសកម្មភាពអភិវឌ្ឍឱ្យបានពេញលេញក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទទទួលបានការអនុញ្ញាតអភិវឌ្ឍនិងផលិតកម្មលើកដំបូង អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតនោះត្រូវប្រគល់តំបន់ចុះកិច្ចព្រមព្រៀងទាំងមូលជូនក្រសួងរ៉ែនិងថាមពលវិញ ហើយកិច្ចព្រមព្រៀងប្រេងកាតត្រូវបានបញ្ចប់។

**មាត្រា២៤ .-**

ក្រសួងរ៉ែនិងថាមពលអាចតម្រូវឱ្យអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតពីរឬច្រើនធ្វើប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍនិងផលិតកម្មលើជម្រកប្រេងកាតមួយ ឬច្រើន ដែលស្ថិតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាតផ្សេងគ្នា ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការអភិវឌ្ឍនិងផលិតកម្មលើជម្រកប្រេងកាតក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាតតែមួយមិនអាចមានលក្ខណៈពាណិជ្ជកម្មហើយតម្រូវឱ្យមានការអភិវឌ្ឍនិងផលិតកម្មរួមលើជម្រកប្រេងកាតទាំងមូលជាមួយនឹងភាគីចុះកិច្ចព្រមព្រៀងប្រេងកាតផ្សេងទៀតដើម្បីឱ្យមានលក្ខណៈពាណិជ្ជកម្ម ឬ

ខ- ការអភិវឌ្ឍនិងផលិតកម្មលើជម្រកប្រេងកាតរួមគ្នាផ្ដល់ផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងប្រសិទ្ធភាពកាន់តែប្រសើរខ្ពស់ជាងប្រតិបត្តិការដាច់ដោយឡែកពីគ្នា។

កិច្ចព្រមព្រៀងអភិវឌ្ឍនិងផលិតកម្មរួមត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលពិនិត្យនិងសម្រេចស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា២៥ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតមានកាតព្វកិច្ចប្រគល់សងវិញនូវចំណែកណាមួយនៃផ្ទៃក្រឡាដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតទៅតាមដំណាក់កាលនីមួយៗនៃប្រតិបត្តិការប្រេងកាត។

ក្រៅពីកាតព្វកិច្ចតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតអាចស្នើសុំទៅរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដើម្បីប្រគល់សងវិញបន្ថែមទៀតដោយស្ម័គ្រចិត្តនូវចំណែកណាមួយឬទាំងមូលនៃផ្ទៃក្រឡាដែលបានចុះកិច្ចព្រមព្រៀងប្រេងកាត។

លក្ខខណ្ឌនិងនីតិវិធីស្ដីពីកាតព្វកិច្ចនៃការប្រគល់ផ្ទៃក្រឡាសងវិញត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៦ .-**

សកម្មភាពផ្នែកអាប់ស្ទ្រីមណាមួយដែលចាំបាច់ត្រូវធ្វើនៅក្នុងឬឆ្លងកាត់តំបន់ការពារធម្មជាតិ តំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ តំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្ត្រ និងតំបន់បេតិកភ័ណ្ឌជាតិ អាចប្រព្រឹត្តទៅបានលុះណាតែមានការឯកភាពជាមុនពីក្រសួងឬស្ថាប័នគ្រប់គ្រងតំបន់ទាំងនោះស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា២៧ ._**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវចរចាជាមួយនឹងម្ចាស់ដីឬអ្នកគ្រប់គ្រងដីស្របច្បាប់ មុននឹងធ្វើសកម្មភាពប្រតិបត្តិការប្រេងកាត ហើយត្រូវទូទាត់សំណងលើការខូចខាតដែលបណ្តាលមកពីប្រតិបត្តិការរបស់ខ្លួន។ ក្នុងករណីដែលពុំមានការព្រមព្រៀង អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតអាចស្នើសុំមកក្រសួងរ៉ែនិងថាមពលដើម្បីសម្របសម្រួលរវាងអ្នកចុះកិច្ចព្រមព្រៀងប្រេងកាត និងម្ចាស់ដីឬអ្នកគ្រប់គ្រងដីស្របច្បាប់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

លក្ខខណ្ឌនិងនីតិវិធីនៃការទូទាត់សំណងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៨ ._**

ទិន្នន័យប្រេងកាតទាំងអស់ដែលទទួលបានពីប្រតិបត្តិការប្រេងកាតគឺជាកម្មសិទ្ធិរបស់រដ្ឋនិងត្រូវគ្រប់គ្រងចាត់ចែងដោយក្រសួងរ៉ែនិងថាមពល។

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតអាចប្រើប្រាស់ទិន្នន័យប្រេងកាតដែលពាក់ព័ន្ធនឹងតំបន់ចុះកិច្ចព្រមព្រៀងក្នុងរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងប្រេងកាត។

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវប្រគល់គ្រប់ទិន្នន័យប្រេងកាតទាំងអស់ពីប្រតិបត្តិការប្រេងកាតជូនក្រសួងរ៉ែនិងថាមពល នៅពេលកិច្ចព្រមព្រៀងប្រេងកាតត្រូវបានបញ្ចប់ ឬផុតសុពលភាព។

**មាត្រា២៩ ._**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវផ្តល់ជូនក្រសួងរ៉ែនិងថាមពលនូវរាល់ព័ត៌មាននិងរបាយការណ៍បច្ចេកទេសពាក់ព័ន្ធនឹងប្រតិបត្តិការប្រេងកាត។

**មាត្រា៣០ ._**

ក្រសួងរ៉ែនិងថាមពលអាចធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាក់ទងនឹងបរិស្ថាននិងសង្គមដែលពាក់ព័ន្ធនឹងប្រតិបត្តិការប្រេងកាត។

**មាត្រា៣១ ._**

រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតផ្គត់ផ្គង់ចំណែកផលប្រេងកាតរបស់ខ្លួនមិនលើស២៥(ម្ភៃប្រាំ)ភាគរយដើម្បីបំពេញតម្រូវការចាំបាច់ក្នុងស្រុក។ ក្នុងករណីមានភាពអាសន្នក្នុងការផ្គត់ផ្គង់ក្នុងប្រទេស ការនាំចេញធនធានប្រេងកាតអាចត្រូវបានហាមឃាត់។

ការចាត់ចែងនិងកាតព្វកិច្ចនៃការបំពេញតម្រូវការក្នុងស្រុកត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣២ ._**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលធ្វើប្រតិបត្តិការប្រេងកាតត្រូវមានធានារ៉ាប់រងលើសុវត្ថិភាពនៃប្រតិបត្តិការប្រេងកាត គ្រឿងបរិក្ខារនិងឋបនកណ្ឌដែលបម្រើឱ្យកិច្ចប្រតិបត្តិការប្រេងកាត លើការខូចខាត បរិស្ថាន និងត្រូវមានធានារ៉ាប់រងផ្សេងៗទៀតស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន និងតាមឧត្តមានុវត្តដែលមានការឯកភាពពីក្រសួងរ៉ែនិងថាមពល។

**មាត្រា៣៣ .-**

ក្នុងករណីមានអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតច្រើនជាងមួយនៅក្នុងកិច្ចព្រមព្រៀងប្រេងកាតមួយ អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតនីមួយៗត្រូវមានកាតព្វកិច្ចទទួលខុសត្រូវដោយសាមគ្គី។

## ជំពូកទី៤
## ការគ្រប់គ្រងចំណូលរដ្ឋពីប្រេងកាត
## និងភាគលាភរបស់រដ្ឋ

**មាត្រា៣៤ .-**

រដ្ឋមានសិទ្ធិក្នុងការចូលរួមភាគហ៊ុនក្នុងប្រតិបត្តិការប្រេងកាត។ ការចូលរួមភាគហ៊ុនរបស់រដ្ឋត្រូវសម្រេចដោយនាយករដ្ឋមន្ត្រី។

**មាត្រា៣៥ .-**

អ្នកដាក់ពាក្យស្នើសុំឬអ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ដែលធ្វើសកម្មភាពផ្នែកអាប់ស្ទ្រីមត្រូវបង់កម្រៃសេវាសាធារណៈ។

បែបបទនិងនីតិវិធីនៃការបង់កម្រៃសេវាសាធារណៈត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៦ .-**

រាជរដ្ឋាភិបាលត្រូវកាត់ទុកនូវសួយសារប្រេងកាត មុនអនុញ្ញាតឱ្យអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតធ្វើការទូទាត់សោហ៊ុយប្រេងកាតនិងបែងចែកផលប្រេងកាត។

ផលប្រេងកាតដែលនៅសល់ក្រោយពីការកាត់ទុកសួយសារនិងការទូទាត់សោហ៊ុយប្រេងកាតត្រូវបានបែងចែកជូនរវាងរាជរដ្ឋាភិបាលនិងអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

អត្រាសួយសារ នីតិវិធី វិធានកំណត់តម្លៃ ការវាស់បរិមាណ និងទីតាំងកំណត់ថ្លៃត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៧ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា៣៨ .-**

សហគ្រាសសាធារណៈនឹងត្រូវបានបង្កើតឡើងស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានដើម្បីធ្វើធុរកិច្ចក្នុងវិស័យប្រេងកាត។

## ជំពូកទី៥
## ការគ្រប់គ្រងសកម្មភាពផ្នែកដោនស្ទ្រីម

**មាត្រា៣៩ .-**

សកម្មភាពផ្នែកដោនស្ទ្រីមរួមមាន ការធ្វើប្រព្រឹត្តិកម្ម ការដឹកជញ្ជូន សន្និធិ និងពាណិជ្ជកម្មប្រេងកាត និងផលិតផលប្រេងកាត លើកលែងតែការលក់និងការនាំចេញប្រេងកាតដែលអនុវត្តស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

**មាត្រា៤០ .-**

សកម្មភាពផ្នែកដោនស្ទ្រីមត្រូវបានអនុញ្ញាតឱ្យអនុវត្តចំពោះ៖

១- រូបវន្តបុគ្គលឬ

២- នីតិបុគ្គលណាមួយដូចខាងក្រោម៖

- សហគ្រាសសាធារណៈបង្កើតឡើងស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន
- ក្រុមហ៊ុនសហកម្មសិទ្ធិនិងក្រុមហ៊ុនមូលធនដែលបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវស្របតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម
- ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលធ្វើសកម្មភាពធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤១ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមត្រូវមានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតពីក្រសួងរ៉ែនិងថាមពលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

រូបវន្តបុគ្គលឬនីតិបុគ្គលអាចស្នើសុំធ្វើសកម្មភាពធុរកិច្ចក្នុងផ្នែកដោនស្ទ្រីមលើសពីមួយបាន ប៉ុន្តែត្រូវមានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតផ្សេងៗគ្នា។

ប្រភេទអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត ការធានារ៉ាប់រង លក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតផ្នែកដោនស្ទ្រីមត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤២ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមត្រូវមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសពីក្រសួងរ៉ែនិងថាមពលមុននឹងចាប់ផ្ដើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធដើម្បីបម្រើសកម្មភាពផ្នែកដោនស្ទ្រីម។

**មាត្រា៤៣ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតផ្នែកដោនស្ទ្រីមដែលមាន

បំណងធ្វើសកម្មភាពផ្នែកអាប់ស្ទ្រីមត្រូវចុះបញ្ជីពាណិជ្ជកម្មជានីតិបុគ្គលដោយឡែកផ្សេងមួយទៀតសម្រាប់ធ្វើសកម្មភាពផ្នែកអាប់ស្ទ្រីមស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៤៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព អាជ្ញាបណ្ណឬលិខិតអនុញ្ញាតធ្វើសកម្មភាពផ្នែកដោនស្ទ្រីមត្រូវបង់កម្រៃសេវាសាធារណៈ។

បែបបទនិងនីតិវិធីនៃការបង់កម្រៃសេវាសាធារណៈត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតមានសិទ្ធិសុំបន្ត កែប្រែសិទ្ធិនិងផលប្រយោជន៍ ដាក់ជាប្រាតិភោគ ផ្ទេរសិទ្ធិ ប្ដូរអំណាចគ្រប់គ្រង ឬបន្តជាសន្តតិកម្មអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតបាន។

លក្ខខណ្ឌនិងនីតិវិធីនៃការសុំបន្ត កែប្រែសិទ្ធិនិងផលប្រយោជន៍ ដាក់ជាប្រាតិភោគ ផ្ទេរសិទ្ធិ ប្ដូរអំណាចគ្រប់គ្រង ឬបន្តជាសន្តតិកម្មត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៤៦.-**

អាជ្ញាបណ្ណឬលិខិតអនុញ្ញាតអាចត្រូវបានព្យួរឬដកហូតក្នុងករណីរូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតមិនបានបំពេញកាតព្វកិច្ចស្របតាមលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណឬលិខិតអនុញ្ញាតនោះ និងបទប្បញ្ញត្តិនៃច្បាប់នេះ។

លក្ខខណ្ឌនិងនីតិវិធីនៃការព្យួរនិងការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧.-**

រាល់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីមដែលមានទុនវិនិយោគចាប់ពី ២០០ ០០០ ០០០ (ពីររយពាន់លាន) រៀលឡើងទៅ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវរៀបចំឱ្យមានការចរចាដោយមានការចូលរួមពីក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជាមួយនឹងបុគ្គលដែលស្នើសុំដើម្បីឈានទៅដល់កិច្ចព្រមព្រៀងវិនិយោគនិងស្នើសុំការឯកភាពពីនាយករដ្ឋមន្ត្រីមុនពេលសម្រេចផ្ដល់អាជ្ញាបណ្ណ។

**មាត្រា៤៨.-**

ក្រសួងរ៉ែនិងថាមពលមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិបច្ចេកទេសផ្នែកដោនស្ទ្រីមមានដូចខាងក្រោម៖

- ...យថាប្រភេទគុណភាពផលិតផលប្រេងកាត
- សន្និធិប្រេងកាតនិងផលិតផលប្រេងកាត
- ការដឹកជញ្ជូនប្រេងកាតនិងផលិតផលប្រេងកាត
- សុវត្ថិភាពនិងការគ្រប់គ្រងស្ថានីយប្រេងកាតនិងផលិតផលប្រេងកាត

- ប្រព្រឹត្តិកម្មប្រេងកាតនិងគីមីប្រេងកាត និង
- បទប្បញ្ញត្តិបច្ចេកទេសផ្នែកដោនស្ទ្រីមផ្សេងៗទៀត។

បទប្បញ្ញត្តិបច្ចេកទេសផ្នែកដោនស្ទ្រីមត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៤៩ .-**

ក្រសួងរ៉ែនិងថាមពលត្រូវរៀបចំផែនការមេរបស់ជាតិស្តីពីការដឹកជញ្ជូននិងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិក្នុងការជំរុញនិងគ្រប់គ្រងការវិនិយោគសាងសង់ប្រព័ន្ធបណ្តាញបំពង់បង្ហូរ និងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិ ។ ក្រសួងរ៉ែនិងថាមពលត្រូវដឹកនាំនិងសម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ចលើការរៀបចំផែនការមេនេះ។

ការអនុញ្ញាតឱ្យផ្នែកឯកជនវិនិយោគសាងសង់ប្រព័ន្ធបណ្តាញបំពង់បង្ហូរនិងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិត្រូវកំណត់ឱ្យតែកំណាត់ផ្នែកណាមួយនៃប្រព័ន្ធទាំងមូល ឬតំបន់ផ្គត់ផ្គង់ពាណិជ្ជកម្មមួយចំនួនតែប៉ុណ្ណោះនិងត្រូវផ្អែកលើលក្ខខណ្ឌបច្ចេកទេស សន្តិសុខនិងសុវត្ថិភាព សេដ្ឋកិច្ចសង្គម និងគោលការណ៍ប្រកួតប្រជែង។

**មាត្រា៥០ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណឬលិខិតអនុញ្ញាតត្រូវមានកាតព្វកិច្ចសំខាន់ៗដូចខាងក្រោម៖

ក- ធ្វើប្រតិបត្តិការឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមលក្ខណៈបច្ចេកទេស ឧត្តមានុវត្ត និងបទដ្ឋានអន្តរជាតិ។

ខ- ធ្វើប្រតិបត្តិការឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពតាមរាល់លិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិទាំងឡាយទាក់ទងនឹងវិស័យបរិស្ថាន។

គ- ការពារសុខភាពនិងសុវត្ថិភាពការងារ។

ឃ- ការពារសុវត្ថិភាពសាធារណៈនៅក្នុងនិងនៅជុំវិញតំបន់ដែលទទួលបានការអនុញ្ញាត។

ង- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកម្លាំងពលកម្ម ទំនិញ និងសេវាកម្មក្នុងស្រុក។

ច- អនុវត្តស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី៦
## អធិការកិច្ច

**មាត្រា៥១ .-**

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលមានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចប្រេងកាតដើម្បីតាមដានស្រាវជ្រាវ ត្រួតពិនិត្យនិងជំរុញការអនុវត្តច្បាប់។

មន្ត្រីអធិការកិច្ចប្រេងកាតទទួលនីតិសម្បទាឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចប្រេងកាតត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**មាត្រា៥២ .-**

មន្ត្រីអធិការកិច្ចប្រេងកាតមានសិទ្ធិស្នើសុំជំនួយសហការពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា៥៣ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចប្រេងកាតត្រូវស្លៀកពាក់ឯកសណ្ឋាន និង/ឬសញ្ញាសម្គាល់ព្រមទាំងមានលិខិតអនុញ្ញាតឱ្យបំពេញបេសកកម្ម។

ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៤ .-**

មន្ត្រីអធិការកិច្ចប្រេងកាតមានសិទ្ធិធ្វើអធិការកិច្ចលើកិច្ចប្រតិបត្តិការទាំងអស់ក្នុងវិស័យប្រេងកាតហើយចាត់វិធានការតាមផ្លូវច្បាប់។

**មាត្រា៥៥ .-**

សិទ្ធិអំណាច តួនាទី ភារកិច្ច និងនីតិវិធីផ្សេងៗក្នុងការអនុវត្តរបស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៦ .-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចប្រេងកាតអាចប្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការទៅក្រសួងរ៉ែនិងថាមពលគិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេច។

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវសម្រេចបណ្តឹងតវ៉ាក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

ក្នុងករណីដែលបុគ្គលមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធី ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី៧

## ទោសប្បញ្ញត្តិ

**មាត្រា៥៧ .-**

ទណ្ឌកម្មលើបទល្មើសក្នុងវិស័យប្រេងកាតនៃច្បាប់នេះរួមមាន ការដកហូតឬព្យួរសិទ្ធិដែលផ្តល់ក្រោមច្បាប់នេះ ការជួសជុលការខូចខាត ការផាកពិន័យ ការរឹបអូសវត្ថុតាង និងទោសដាក់ពន្ធនាគារ។

ការដកហូតឬព្យួរសិទ្ធិដែលផ្តល់ក្រោមច្បាប់នេះ ការតម្រូវឱ្យធ្វើការជួសជុលការខូចខាត និងការផាកពិន័យ លើបទល្មើសក្នុងវិស័យប្រេងកាតជាសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល។

នីតិវិធីនៃការផាកពិន័យនិងការដកហូតឬព្យួរសិទ្ធិដូចមានចែងក្នុងច្បាប់នេះត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

ប្រាក់ផាកពិន័យ ប្រាក់ពិន័យតាមសាលក្រមឬសាលដីការបស់តុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋត្រូវបង់ចូលថវិកាជាតិ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យប្រេងកាត។

មន្ត្រីរាជការណាដែលប្រព្រឹត្តបទល្មើសក្នុងវិស័យប្រេងកាតត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមានដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចអំពីទណ្ឌកម្មរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលដូចមានចែងក្នុងច្បាប់នេះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០ (សាម សិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេច។

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**មាត្រា៥៨ .-**

រូបវន្តបុគ្គលណាដែលធ្វើសកម្មភាពស្វែងរុករក អភិវឌ្ឍ ឬផលិតកម្មប្រេងកាត ដោយគ្មានកិច្ចព្រមព្រៀងប្រេងកាត ឬកិច្ចព្រមព្រៀងប្រេងកាតត្រូវបានព្យួរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ២៥០ ០០០ ០០០ (ពីររយហាសិបលាន) រៀល។

ចំពោះនីតិបុគ្គលដែលធ្វើសកម្មភាពស្វែងរុករក អភិវឌ្ឍ ឬផលិតកម្មប្រេងកាតដោយគ្មានកិច្ចព្រមព្រៀងប្រេងកាត ឬកិច្ចព្រមព្រៀងប្រេងកាតត្រូវបានព្យួរ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល ទៅ៤០ ០០០ ០០០ ០០០ (សែសិបពាន់លាន) រៀល។

**មាត្រា៥៩ .-**

រូបវន្តបុគ្គលណាដែលធ្វើសកម្មភាពបុរេសនាក្នុងផ្នែកអាប់ស្ទ្រីមដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី១០ ០០០ ០០០ (ដប់លាន) រៀល ទៅ៥០ ០០០ ០០០ (ហាសិបលាន) រៀល។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន) រៀល។

ចំពោះនីតិបុគ្គលដែលធ្វើសកម្មភាពបុរេសនាក្នុងផ្នែកអាប់ស្ទ្រីមដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល។

**មាត្រា៦០ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលមិនបំពេញកាតព្វកិច្ចដូចមានចែងក្នុងចំណុច ក ឬ ខ នៃមាត្រា២០ នៃច្បាប់នេះ ហើយធ្វើឱ្យខូចខាតដល់បរិស្ថាន ដោយការធ្វេសប្រហែស ឬដោយចេតនាត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី៤០០ ០០០ ០០០ (បួនរយលាន) រៀល ទៅ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល និងត្រូវព្យួរឬបញ្ចប់កិច្ចព្រមព្រៀងប្រេងកាត។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនទ្វេដង។

**មាត្រា៦១ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលមិនបំពេញកាតព្វកិច្ចដូចមានចែងក្នុងចំណុច គ ឬ ឃ នៃមាត្រា២០ នៃច្បាប់នេះ ហើយនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ឬបណ្តាលឱ្យអ្នកដទៃស្លាប់ ដោយការធ្វេសប្រហែសឬដោយចេតនាត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី៤០០ ០០០ ០០០ (បួនរយលាន) រៀល ទៅ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល និងព្យួរឬបញ្ចប់កិច្ចព្រមព្រៀងប្រេងកាត។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនទ្វេដង។

**មាត្រា៦២ .-**

ការក្លែងបន្លំរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងវិស័យប្រេងកាតត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បុគ្គលណាដែលផ្សព្វផ្សាយឬចែកចាយទិន្នន័យប្រេងកាតដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ទៅ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី១០ ០០០ ០០០ (ដប់លាន) រៀល ទៅ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល។

បុគ្គលណាដែលប្រគល់ ឬផ្ដល់របាយការណ៍ ទិន្នន័យ ឬព័ត៌មានក្នុងវិស័យប្រេងកាត ក្នុងគោលបំណងបំភាន់ឬធ្វើឱ្យមានការយល់ខុសដល់ក្រសួងរ៉ែនិងថាមពលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល។

**មាត្រា៦៣ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលយឺតយ៉ាវមិនបានផ្ដល់ទិន្នន័យប្រេងកាត ព័ត៌មាននិងរបាយការណ៍បច្ចេកទេសណាមួយ ឬទាំងអស់ពីប្រតិបត្តិការប្រេងកាតជូនក្រសួងរ៉ែនិងថាមពលតាមពេលវេលាកំណត់ដូចមានចែងក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬក្រោយពីទទួលបានការកំណត់ជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលក្នុងអំឡុងពេលយ៉ាងយូរ៩០ (កៅសិប)ថ្ងៃ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល។

បន្ទាប់ពីទទួលរងការផាកពិន័យតាមកថាខណ្ឌទី១ខាងលើរួចហើយ អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតនៅតែមិនប្រគល់ទិន្នន័យប្រេងកាត ព័ត៌មាននិងរបាយការណ៍បច្ចេកទេស ក្នុងអំឡុងពេលយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល និងត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ៣០០ ០០០ ០០០ (បីរយលាន) រៀល ចំពោះនីតិបុគ្គល។ រាល់ទិន្នន័យប្រេងកាត ព័ត៌មាននិងរបាយការណ៍បច្ចេកទេស និងសម្ភារបច្ចេកទេសដែលពាក់ព័ន្ធត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

ក្នុងករណីអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវបានផ្ដន្ទាទោសស្របតាមកថាខណ្ឌទី២ ខាងលើ សិទ្ធិប្រើប្រាស់ទិន្នន័យប្រេងកាតដែលពាក់ព័ន្ធនឹងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាតត្រូវបានដកហូត។

**មាត្រា៦៤ .-**

បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានអាជ្ញាបណ្ណស្របតាមកថាខណ្ឌទី១ នៃមាត្រា៤១ នៃច្បាប់នេះត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី១ ០០០ ០០០ (មួយលាន) រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន) រៀល។

បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានលិខិតអនុញ្ញាតស្របតាមកថាខណ្ឌទី១ នៃមាត្រា៤១ នៃច្បាប់នេះត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី២០០ ០០០ (ពីររយពាន់) រៀល ទៅ១០ ០០០ ០០០ (ដប់លាន) រៀល។

**មាត្រា៦៥ .-**

បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយពុំគោរពតាមបទប្បញ្ញត្តិបច្ចេកទេសដែលចេញ

ដោយក្រសួងរ៉ែនិងថាមពលស្របតាមមាត្រា៤៨ នៃច្បាប់នេះត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនពី១ ០០០ ០០០ (មួយលាន) រៀល ទៅ៥០ ០០០ ០០០ (ហាសិបលាន) រៀល។

**មាត្រា៦៦ .-**

បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ពីក្រសួងរ៉ែនិងថាមពលដូចមានចែងក្នុងមាត្រា៤២ នៃច្បាប់នេះ មុននឹងចាប់ផ្តើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធដើម្បីបម្រើសកម្មភាពផ្នែកដោនស្ទ្រីម ត្រូវផាកពិន័យជាប្រាក់ដូចខាងក្រោម៖

ក- ចំពោះហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃក្រោម៨០០ ០០០ ០០០ (ប្រាំបីរយលាន) រៀល ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួន៤ ០០០ ០០០ (បួនលាន) រៀល និងត្រូវផ្អាកសកម្មភាពសាងសង់នានា។

ខ- ចំពោះហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃចាប់ពី៨០០ ០០០ ០០០ (ប្រាំបីរយលាន) រៀល ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួន១០ ០០០ ០០០ (ដប់លាន) រៀល និងត្រូវផ្អាកសកម្មភាពសាងសង់នានា។

ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផាកពិន័យជាប្រាក់ដោយក្រសួងរ៉ែនិងថាមពលចំនួនទ្វេដង។

**មាត្រា៦៧ .-**

បុគ្គលណាដែលធ្វើសកម្មភាពរារាំង ឬបង្កឱ្យមានការរាំងស្ទះដល់ដំណើរការ នៃការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចប្រេងកាតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ទៅ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន) រៀល ទៅ៥០ ០០០ ០០០ (ហាសិបលាន) រៀល។ អំពើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ទៅ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ២៥០ ០០០ ០០០ (ពីររយហាសិបលាន) រៀល ប្រសិនបើប្រព្រឹត្តដោយមន្ត្រីរាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតនៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

**មាត្រា៦៨ .-**

ការផាកពិន័យដែលចែងក្នុងជំពូកនេះមិនរាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាននិងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៦៩ .-**

កាតព្វកិច្ច ការទទួលខុសត្រូវ សិទ្ធិនិងផលប្រយោជន៍នានាកំណត់ក្នុងកិច្ចព្រមព្រៀងប្រេងកាតដែលនៅមានសុពលភាពមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តមានសុពលភាពស្របតាមច្បាប់នេះ។ ក្នុងករណីមានបដិប្បញ្ញត្តិជាមួយនឹងច្បាប់នេះ កិច្ចព្រមព្រៀងប្រេងកាតនោះត្រូវធ្វើការកែសម្រួលឡើងវិញដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៧០ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលពុំមានអាជ្ញាបណ្ណឬលិខិតអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៤១ នៃច្បាប់នេះត្រូវបំពេញបែបបទស្នើសុំអាជ្ញាបណ្ណឬលិខិតអនុញ្ញាតឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល១(មួយ)ឆ្នាំ ក្រោយពេលច្បាប់នេះចូលជាធរមាន។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៧១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា៧២ .-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៩

នស/រកម.០៧១៩.០១០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**